## *កិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េ លើកទី ២*

នាព្រឹកថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២០, ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ បន្តចូលរួមកិច្ចប្រជុំកំពូល "**មេគង្គ-សាធារណរដ្ឋកូរ៉េ លើកទី ២**" តាមប្រព័ន្ធវីដេអូ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ កិច្ចប្រជុំនេះដឹកនាំដោយសហប្រធានឯកឧត្តម **ង្វៀន សួន ហ៊្វុក (Nguyen Xuan Phuc)** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងឯកឧត្តម **ម៉ូន ចេ អ៊ីន** (Moon Jae-In) ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ ។

លើប្រធានបទ "**ការពិនិត្យឡើងវិញលើវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ និងទិសដៅអនាគត**", ថ្នាក់ដឹកនាំនៃប្រទេសក្នុងតំបន់មេគង្គ ពិភាក្សាលើកិច្ចសហប្រតិបត្តិការរវាងប្រទេសក្នុងតំបន់មេគង្គ និងសាធារណរដ្ឋកូរ៉េ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដោយសម្រេចបាននូវសមិទ្ធផល និងវឌ្ឍនភាពជាសារវ័ន្ត ជាច្រើន ដូចជា "**សេចក្តីប្រកាសស្តីពីទន្លេមេគង្គ-ហាន ដើម្បីបង្កើតភាពជាដៃគូសម្រាប់ប្រជាជន វិបុលភាព និងសន្តិភាព**", "**ផែនការសកម្មភាពមេគង្គ-សាធារណរដ្ឋកូរ៉េ ២០១៧-២០២០**", កិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការទប់ស្កាត់ជំងឺឆ្លង និងគ្រោះធម្មជាតិ, និងគំនិតផ្តួចផ្តើមផ្សេងទៀតក្នុងតំបន់មេគង្គ ជាដើម ។

ថ្នាក់ដឹកនាំនៃប្រទេសក្នុងតំបន់មេគង្គ បានស្វាគមន៍ចំពោះការអនុម័ត "**ផែនការសកម្មភាពមេគង្គ-សាធារណរដ្ឋកូរ៉េថ្មី ២០២១-២០២៥**", និងលើកកម្ពស់ "**គោលនយោបាយឆ្ពោះទៅទិសខាងត្បូងថ្មី**" ទៅជា "**គោលនយោបាយឆ្ពោះទៅទិសខាងត្បូងថ្មីបូក**" ។

ដោយឈរលើស្មារតីសាមគ្គីភាព និងសហប្រតិបត្តិការខ្ពស់រវាងប្រទេសក្នុងតំបន់មេគង្គ និងសាធារណរដ្ឋកូរ៉េ, ថ្នាក់ដឹកនាំទាំងអស់ បានសម្តែងនូវការប្តេជ្ញាចិត្តខ្ពស់ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធបន្ថែមទៀត តាមរយៈការសម្រេចអនុម័ត "**សេចក្តីប្រកាសរួមស្តីពីកិច្ចប្រជុំកំពូលមេគង្គ-អាស៊ាន លើកទី ២** " និងការជំរុញលើកកម្ពស់ "***ភាពជាដៃគូមេគង្គ-សាធារណរដ្ឋកូរ៉េ***" ឱ្យក្លាយជា "***ភាពជាដៃគូដែលមានកម្រិតជាយុទ្ធសាស្ត្រ***"។

ថ្នាក់ដឹកនាំនៃប្រទេសក្នុងតំបន់មេគង្គ ក៏បានសម្តែងនូវការពេញចិត្ត និងគាំទ្រចំពោះការប្តេជ្ញាចិត្តរបស់ឯកឧត្តម **ម៉ូន ចេ អ៊ីន** ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ ក្នុងការ÷ ១. ពង្រឹងសហប្រតិបត្តិការផ្នែកធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជាពិសេស ពាក់ព័ន្ធនឹងការទប់ស្កាត់នឹងជំងឺឆ្លង, ២. ពង្រឹងការតភ្ជាប់ប្រទេសក្នុងតំបន់ តាមរយៈការអភិវឌ្ឍ វិស័យគមនាគមន៍, ហេដ្ឋារចនាសម្ព័ន្ធទំនើបៗ (ដូចជា ទីក្រុងឆ្លាតវៃ, កសិដ្ឋានឆ្លាតវៃ និងវិស័យផ្សេងទៀត ជាដើម, និង ៣. ធ្វើជាដៃគូជាមួយប្រទេសក្នុងតំបន់មេគង្គក្នុងការធានាការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព ជាពិសេស ពាក់ព័ន្ធនឹងធនធានទឹក ថាមពល និងសន្តិសុខស្បៀង ។